**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ..៤០៣៤..... PC.អក

# សេចក្តីជូនដំណឹង (លើកទី ២)

## ស្តីពី

ការងារសាងសង់អគារស្នាក់ការ, ធ្វើរបងព័ទ្ធជុំវិញដីស្នាក់ការចំនួន ០២ កន្លែង នៅក្រុងពោធិ៍សាត់, ស្រុកភ្នំក្រវាញ និង ធ្វើឃ្លាំងដាក់សម្ភារអគ្គិសនីចំនួន ០៧ កន្លែង (ស្នាក់ការស្រុកបរវេល, ស្នាក់ការមោងឫស្សី, ស្នាក់ការស្រុករតនមណ្ឌល, ស្នាក់ការស្រុកក្រគរ, ស្នាក់ការស្រុកបាកាន, ស្នាក់ការស្រុកភ្នំក្រវាញ, និងស្នាក់ការក្រុងពោធិ៍សាត់) ជូន អគ្គិសនីបាត់ដំបង

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារសាងសង់អគារស្នាក់ការ, ធ្វើរបងព័ទ្ធជុំវិញដីស្នាក់ការចំនួន ០២ កន្លែង នៅក្រុងពោធិ៍សាត់, ស្រុកភ្នំក្រវាញ និងធ្វើឃ្លាំង ដាក់សម្ភារអគ្គិសនីចំនួន ០៧ កន្លែង (ស្នាក់ការស្រុកបរវេល, ស្នាក់ការមោងឫស្សី, ស្នាក់ការស្រុករតនមណ្ឌល, ស្នាក់ការស្រុកក្រគរ, ស្នាក់ការស្រុកបាកាន, ស្នាក់ការស្រុកភ្នំក្រវាញ, និងស្នាក់ការក្រុងពោធិ៍សាត់) ជូន អគ្គិសនីបាត់ដំបង ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី 26 ខែ សីហា ឆ្នាំ ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 / 092 652 357 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២០ វេលាម៉ោង ១៤:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង ១៥:០០ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២០ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ១០កើត ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២០
**ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហង់ ធុច**

ចម្លងជូន ៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ